


ការចូលក្នុងនគរព្រះប្រកបដោយអំណាច



ការបង្រៀនតាមរយៈសំបុត្រ ដោយ ដេរេក ព្រីនស៍

នៅសម័យនេះ ការត្រឡប់ទៅកាន់មូលដ្ឋានគ្រឹះវិញ គឺជារឿងបន្ទាន់បំផុត។ ហេតុអ្វី? ពីព្រោះសេចក្តីពិតជាមូលដ្ឋាននៃជំនឿរបស់យើង ដែលយើងកាន់ខ្ជាប់យ៉ាងមាំមួននៅក្នុងចិត្ត និងគំនិតរបស់យើង នឹងអនុញ្ញាតឲ្យយើងបន្តដំណើរទៅមុខដោយជោគជ័យក្នុងជីវិតគ្រីស្ទបរិស័ទ។

ប្រសិនបើយើងពិតជាកំពុងខិតជិតដល់ចុងបញ្ចប់នៃពិភពលោកមែន យើងត្រូវរៀបចំខ្លួនសម្រាប់ចម្រូតដ៏ធំមហិមា។ នៅក្នុងសំបុត្របង្រៀននេះ លោក ដេរេក ព្រីនស៍ រំឭកយើងអំពីភារកិច្ចដ៏សំខាន់របស់យើង គឺឃើញជីវិតមនុស្សត្រូវបានផ្លាស់ប្រែ នៅពេលដែលមនុស្សរាប់រយ ឬរាប់ពាន់នាក់មករកព្រះយេស៊ូវគ្រីស្ទ។ ហើយនៅពេលពួកគេមក ពួកគេត្រូវការទទួលបទពិសោធន៍នៃ «ការចូលទៅក្នុងនគរព្រះប្រកបដោយអំណាច»។

ព្រះវិញ្ញាណបរិសុទ្ធយាងមក

សូមឲ្យយើងចាប់ផ្តើមដោយពិនិត្យមើលបទគម្ពីរមួយនៅក្នុងកិច្ចការ ជំពូក ២ ដែលកត់ត្រាអំពីថ្ងៃបុណ្យទី៥០ (Pentecost) ដំបូងបង្អស់។ បន្ទាប់ពីព្រះយេស៊ូវបានយាងឡើងទៅស្ថានសួគ៌ ពួកសិស្សរបស់ទ្រង់បានប្រមូលផ្តុំគ្នានៅក្នុងបន្ទប់ខាងលើមួយ។ ព្រះវិញ្ញាណបរិសុទ្ធបានយាងចុះមកលើពួកសិស្ស ដូចដែលព្រះយេស៊ូវបានសន្យាទុក ហើយជាលើកដំបូង ពួកគេចាប់ផ្តើមនិយាយភាសាផ្សេងៗ។

នៅក្បែរបន្ទប់ជាន់លើនោះ មានជនជាតិយូដាដែលគោរពកោតខ្លាចព្រះ មកពីប្រទេសជាច្រើន កំពុងស្ថិតនៅក្នុងក្រុងយេរូសាឡិម រួមជាមួយអ្នកស្រុកដែលរស់នៅទីនោះផងដែរ។ នៅពេលព្រះវិញ្ញាណបរិសុទ្ធយាងចុះមកសណ្ឋិតលើពួកសិស្ស ជនជាតិយូដាដែលបានធ្វើដំណើរមកកាន់ក្រុងយេរូសាឡិមទាំងនោះ បានឮពួកសិស្សនិយាយជាភាសាកំណើតរបស់ខ្លួន។ ពួកគេមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ហើយបានសួរថា «តើការនេះដូចម្តេចហ្ន៎?» (កិច្ចការ ២:១២)។ នៅពេលនោះ សាវ័កពេត្រុសបានក្រោកឈរឡើង ហើយចាប់ផ្តើមពន្យល់អំពីហេតុការណ៍ដែលកំពុងកើតឡើង ដោយដកស្រង់ពីសេចក្តីទំនាយរបស់ហោរាយ៉ូអែល និងពីគម្ពីរទំនុកតម្កើង។ នៅចុងបញ្ចប់ លោកបានមានប្រសាសន៍ថា៖

> ដូច្នេះ ចូរឲ្យពួកវង្សអ៊ីស្រាអែលទាំងអស់ដឹងជាប្រាកដថា ព្រះទ្រង់បានលើកព្រះយេស៊ូវនេះ ដែលអ្នករាល់គ្នាបានឆ្កាង ឲ្យទ្រង់ធ្វើជាព្រះអម្ចាស់ ហើយជាព្រះគ្រីស្ទផង។ (កិច្ចការ ២:៣៦)

«តើយើងត្រូវធ្វើដូចម្តេច?»

យើងបន្តតាមដានដំណើររឿងនេះ ដោយពិនិត្យមើលការឆ្លើយតបរបស់អ្នកដែលបានស្តាប់សេចក្តីអធិប្បាយរបស់សាវ័កពេត្រុស នៅក្នុងគម្ពីរកិច្ចការ ២:៣៧–៣៨៖

> កាលគេបានឮ នោះគេមានសេចក្តីចាក់ចុចក្នុងចិត្ត ក៏សួរពេត្រុស នឹងពួកសាវកឯទៀតថា បងប្អូនអើយ តើយើងខ្ញុំត្រូវធ្វើដូចម្តេច ពេត្រុសឆ្លើយតបថា ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាម

> ព្រះយេស៊ូវគ្រីស្ទ ប្រយោជន៍ឲ្យបានរួចពីបាប នោះអ្នករាល់គ្នានឹងទទួលអំណោយទាន ជាព្រះវិញ្ញាណបរិសុទ្ធ។

សូមចងចាំថា មនុស្សដែលសាវ័កពេត្រុសកំពុងមានប្រសាសន៍ទៅកាន់នោះ គឺជាបុរស និងស្ត្រីជនជាតិយូដា ដែលមានភក្តីភាពចំពោះបទគម្ពីរ និងជំនឿសាសនាយូដា។ ពួកគេបានធ្វើដំណើរមកជួបជុំគ្នានៅក្រុងយេរូសាឡិម ក្នុងពេលនោះ ជាពិសេសដើម្បីចូលរួមប្រារព្ធពិធីបុណ្យសាសនាមួយ។

ទោះជាយ៉ាងណាក៏ដោយ នៅពេលសាវ័កពេត្រុសបានប្រកាសសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះ ក្រោមការចាក់ប្រេងតាំងនៃព្រះវិញ្ញាណបរិសុទ្ធដល់ពួកគេ នោះពួកគេបានដឹងភ្លាមៗថា ខ្លួនមិនទាន់មានទំនាក់ទំនងដ៏ត្រឹមត្រូវជាមួយព្រះជាម្ចាស់នៅឡើយទេ។ ពួកគេមិនទាន់បានទទួលស្គាល់ព្រះមេស្ស៊ី ដែលព្រះជាម្ចាស់បានសន្យាទុក គឺព្រះយេស៊ូវជាអ្នកភូមិណាសារ៉ែតនោះឡើយ។

ពួកអ្នកចំណាកស្រុកសាសន៍យូដាទាំងនេះ គឺនៅឆ្ងាយពីព្រះ។ ពួកគេកំពុងឈរនៅខាងក្រៅព្រះគុណរបស់ព្រះ មិនមានទំនាក់ទំនងត្រឹមត្រូវជាមួយព្រះ ហើយក៏មិនមានការធានាថាបាបរបស់ខ្លួនត្រូវបានអត់ទោសដែរ។ ដូចមនុស្សជាច្រើននៅសព្វថ្ងៃនេះដែរ ពួកគេមិនបានដឹងពីស្ថានភាពពិតរបស់ខ្លួនទេ រហូតដល់ព្រះបន្ទូលរបស់ព្រះត្រូវបានប្រកាសដល់ពួកគេ ដោយការចាក់ប្រេងតាំងនៃព្រះវិញ្ញាណបរិសុទ្ធ។ នៅក្នុងកិច្ចការ ២:៣៧ ពិពណ៌នាអំពីឥទ្ធិពលនៃសារដែលពោរពេញដោយការចាក់ប្រេងតាំងនោះថា៖ នោះគេមានសេចក្តីចាក់ចុចក្នុងចិត្ត។

ដាវមុខពីរដ៏មុតស្រួចនៃព្រះវិញ្ញាណរបស់ព្រះ (ហេព្រើរ ៤:១២) បានចាក់ទម្លុះចូលដល់ចិត្តរបស់ពួកគេ ហើយបានបង្ហាញឲ្យឃើញថា ការពឹងផ្អែកលើដើមកំណើត និងការគោរពប្រតិបត្តិតាមបែបសាសនា មិនអាចធ្វើឲ្យពួកគេត្រឹមត្រូវនៅចំពោះព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់បានឡើយ។ នៅពេលពួកគេដឹងការពិតដ៏ច្បាស់លាស់នេះ ពួកគេក៏បានសួរសំណួរដ៏សំខាន់មួយថា៖ «តើយើងត្រូវធ្វើដូចម្តេច?»

ការឈានមកដល់ចំណុចដែលដឹងថាខ្លួនមានសេចក្តីត្រូវការ

មនុស្សភាគច្រើនត្រូវធ្វើដំណើរយ៉ាងវែងឆ្ងាយក្នុងជីវិត ដោយឆ្លងកាត់ទាំងជោគជ័យ និងបរាជ័យជាច្រើន មុននឹងមកដល់ចំណុចនេះ។ ជាញឹកញាប់ មនុស្សម្នាក់ៗត្រូវប្រព្រឹត្តកំហុសជាច្រើន និងរងការខកចិត្តម្តងហើយម្តងទៀត មុននឹងពួកគេឈានមកដល់ចំណុចដែលសួរខ្លួនឯងនូវសំណួរនេះថា៖ «តើយើងត្រូវធ្វើដូចម្តេច?»

ការផ្លាស់ប្រែដ៏ពិតប្រាកដ ចាប់ផ្តើមឡើងជាមួយនឹងសំណួរដ៏ស្មោះត្រង់បែបនេះ៖ «តើខ្ញុំអាចផ្លាស់ប្តូរទំនាក់ទំនងរបស់ខ្ញុំជាមួយព្រះដោយរបៀបណា? តើខ្ញុំអាចមានទំនាក់ទំនងត្រឹមត្រូវជាមួយទ្រង់ដោយរបៀបណា? តើខ្ញុំអាចទទួលការអត់ទោស ការសង្គ្រោះ និងព្រះគុណរបស់ទ្រង់ដោយរបៀបណា? តើព្រះទាមទារអ្វីពីខ្ញុំ?» ខ្ញុំជឿជាក់យ៉ាងមុតមាំថា នៅពេលណាមនុស្សម្នាក់សួរសំណួរទាំងនេះដោយចិត្តស្មោះត្រង់ ព្រះជាម្ចាស់ក៏បានត្រៀមចម្លើយរួចជាស្រេចសម្រាប់គាត់ហើយ។

តម្រូវការបីយ៉ាង

ក្នុងនាមជាអ្នកនាំព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក្រោមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ សាវ័កពេត្រុសស្ថិតនៅក្នុងទីតាំងដ៏សមស្របបំផុត ដើម្បីឆ្លើយតបទៅនឹងសំណួររបស់អ្នកស្តាប់ទាំងនោះ។ នៅក្នុងគម្ពីរកិច្ចការ ២:៣៨ លោកបានផ្តល់ចម្លើយមួយយ៉ាងច្បាស់លាស់ ជាក់លាក់ និងមិនស្រពេចស្រពិលឡើយ។

> ពេត្រុសឆ្លើយតបថា ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ប្រយោជន៍ឲ្យបានរួចពីបាប នោះអ្នករាល់គ្នានឹងទទួលអំណោយទាន ជាព្រះវិញ្ញាណបរិសុទ្ធ ។

នៅក្នុងផ្នែកខាងក្រោមនេះ ខ្ញុំបានរៀបចំចម្លើយរបស់ពេត្រុសជាបីជំហាន តាមលំដាប់ដែលគាត់បានលើកឡើង៖

1. ជំហាន ទី១៖ ប្រែចិត្ត ។
2. ជំហាន ទី២៖ ទទួលបុណ្យជ្រមុជទឹក។
3. ជំហាន ទី៣៖ ទទួលអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ។

និយាយដោយសាមញ្ញ លោក ពេត្រុស កំពុងមានប្រសាសន៍ថា៖ «ប្រសិនបើអ្នកកំពុងសួរថា តើត្រូវធ្វើដូចម្តេច នេះគឺជាអ្វីដែលព្រះទាមទារពីអ្នក៖ ចូរប្រែចិត្ត ចូរទទួលបុណ្យជ្រមុជទឹក ហើយចូរទទួលព្រះវិញ្ញាណបរិសុទ្ធ»។

លទ្ធផលដូចគ្នា

ដោយផ្អែកលើព្រះបន្ទូលរបស់ព្រះ នេះគឺជាអ្វីដែលអ្នកអាចរំពឹងទុកបាន។ ប្រសិនបើអ្នកប្រាថ្នាយ៉ាងស្មោះអស់ពីចិត្ត ចង់មានទំនាក់ទំនងត្រឹមត្រូវជាមួយព្រះ ទ្រង់នឹងប្រទានចម្លើយដដែលដល់អ្នកនៅថ្ងៃនេះ ដូចដែលពេត្រុសបានផ្តល់ដល់មនុស្សទាំងនោះនៅក្រុងយេរូសាឡិម ក្នុងថ្ងៃបុណ្យទី៥០ដែរ។ អ្នកត្រូវតែប្រែចិត្ត អ្នកត្រូវតែទទួលបុណ្យជ្រមុជទឹក ហើយអ្នកនឹងទទួលអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ។

មនុស្សជាច្រើនប្រហែលជានិយាយថា៖ «អើ! អ្វីដែលអ្នកត្រូវធ្វើ គឺគ្រាន់តែប្រែចិត្តប៉ុណ្ណោះ»។ អ្នកខ្លះទៀតអាចនិយាយថា៖ «អើ! អ្នកត្រូវតែប្រែចិត្តជាមុនសិន ហើយនៅពេលព្រះវិហាររៀបចំពិធីបុណ្យជ្រមុជទឹក អ្នកអាចចុះឈ្មោះជាបេក្ខជន ដើម្បីទទួលបុណ្យជ្រមុជទឹកបាន»។ រីឯអ្នកខ្លះទៀតដែលមានជំនឿតាមចលនាខារីស្មាទិក ប្រហែលជានិយាយថា៖ «នៅពេលសមស្រប យើងនឹងពន្យល់អ្នកបន្ថែមអំពីបទពិសោធន៍ខាងវិញ្ញាណមួយទៀត ដែលហៅថា ការទទួលបុណ្យជ្រមុជក្នុងព្រះវិញ្ញាណបរិសុទ្ធ»។

ប៉ុន្តែ ព្រះជាម្ចាស់មិនបានបង្ហាញរឿងនេះតាមរបៀបនោះទាល់តែសោះ។ តាមរយៈសាវ័កពេត្រុស ព្រះអង្គបានមានបន្ទូលថា៖ «ចូរប្រែចិត្ត ទទួលបុណ្យជ្រមុជទឹក ហើយទទួលព្រះវិញ្ញាណបរិសុទ្ធ»។ ខ្ញុំចង់បញ្ជាក់អំពីសេចក្តីពិតមួយដែលមិនអាចប្រកែកបាន។ នៅថ្ងៃបុណ្យទីហាសិប មនុស្សបីពាន់នាក់បានអនុវត្តទាំងបីចំណុចនេះ។ ពួកគេទាំងអស់គ្នាបានប្រែចិត្ត ពួកគេទាំងអស់គ្នាបានទទួលបុណ្យជ្រមុជទឹក ហើយខ្ញុំផ្ទាល់មានជំនឿយ៉ាងមុតមាំថា ពួកគេទាំងអស់គ្នាក៏បានទទួលព្រះវិញ្ញាណបរិសុទ្ធផងដែរ។ ការទាំងបីនេះមិនត្រូវបានបែងចែកជាដំណាក់កាលបន្តបន្ទាប់ ដែលពួកគេអាចអនុវត្តបន្តិចម្តងៗ ឬតាមពេលវេលាដែលខ្លួនងាយស្រួលនោះឡើយ។

ចម្លើយដែលព្រះបានប្រទាន គឺពេញលេញ ខ្លី និងច្បាស់លាស់ មានតែតម្រូវការបីប៉ុណ្ណោះ៖ ប្រែចិត្ត ទទួលបុណ្យជ្រមុជទឹក ហើយទទួលអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ។

ការអធិស្ឋានសម្រាប់អ្នក

តើអ្នកមានបំណងចង់ចូលរួមចំណែកក្នុងការប្រមូលផលដ៏ធំដែលនឹងមកដល់ដែរឬទេ? តើអ្នកចង់ឃើញមនុស្សរាប់រយនាក់ ឬសូម្បីតែរាប់ពាន់នាក់ បានឆ្លងកាត់បទពិសោធន៍នៃអំណោយទានដ៏អស្ចារ្យ គឺការចូលទៅក្នុងនគរដ៏រុងរឿងរបស់ព្រះជាម្ចាស់ប្រកបដោយអំណាចដែរឬទេ?

ប្រហែលជាអ្នកកំពុងអានសំបុត្រនេះ ដើម្បីឱ្យខ្លួនឯងមានការយល់ដឹងកាន់តែច្បាស់អំពីអត្ថន័យនៃការចូលទៅក្នុងនគរព្រះយ៉ាងពេញលេញ។ ឬមួយ អ្នកប្រហែលជាមានបំណងចង់បង្កើនសមត្ថភាពរបស់ខ្លួនក្នុងការពន្យល់ដល់អ្នកដទៃឱ្យកាន់តែច្បាស់អំពីផ្លូវនៃសេចក្តីសង្គ្រោះ និងការចូលទៅក្នុងនគរព្រះ ខណៈពេលដែលព្រះជាម្ចាស់កំពុងចាក់បង្ហូរព្រះវិញ្ញាណរបស់ព្រះអង្គនៅទូទាំងពិភពលោក។

ទោះជាក្នុងករណីណាក៏ដោយ ខ្ញុំនឹងមានកិត្តិយសយ៉ាងខ្លាំង ប្រសិនបើអ្នកអនុញ្ញាតឱ្យខ្ញុំមានឱកាសអធិស្ឋានសម្រាប់អ្នក ដោយទូលសូមឱ្យព្រះជាម្ចាស់ជួយអ្នកឱ្យយល់ និងអនុវត្តតាមសេចក្តីពិតទាំងឡាយដែលខ្ញុំបានចែករំលែកនៅទីនេះ។

ព្រះវរបិតានៃយើងខ្ញុំនៅស្ថានសួគ៌អើយ! យើងខ្ញុំសូមអរព្រះគុណទ្រង់ ចំពោះភាពច្បាស់លាស់នៃព្រះបន្ទូលរបស់ទ្រង់។ យើងខ្ញុំសូមអរព្រះគុណទ្រង់ ដែលទ្រង់បានបង្ហាញយ៉ាងច្បាស់នូវអ្វីដែលទ្រង់តម្រូវពីយើង ទាំងតាមរយៈសេចក្តីបង្រៀន និងតាមរយៈគំរូដែលទ្រង់បានប្រទាន។

ទូលបង្គំ អធិស្ឋានសម្រាប់មនុស្សដែលកំពុងអានសេចក្តីនេះ សូមឲ្យព្រះវិញ្ញាណរបស់ព្រះធ្វើឲ្យតម្រូវការទាំងនេះមានភាពច្បាស់លាស់ដូចកញ្ចក់ថ្លា។

ឱព្រះជាម្ចាស់អើយ សូមបង្ហាញមនុស្សម្នាក់ៗឲ្យឃើញថា ខ្លួនកំពុងឈរនៅកន្លែងណាចំពោះព្រះភក្ត្រទ្រង់។ សូមប្រទានកម្លាំងដល់អស់អ្នកដែលមានឆន្ទៈស្តាប់បង្គាប់ និងធ្វើតាមអ្វីដែលទ្រង់ទាមទារ ស្របតាមព្រះបន្ទូលរបស់ទ្រង់ ដើម្បីឲ្យពួកគេទទួលបានការរំដោះយ៉ាងពេញលេញពីលោកិយនេះ និងបានចូលទៅក្នុងនគររបស់ព្រះ។

ព្រះអម្ចាស់អើយ ក្នុងគ្រប់ការទាំងអស់ដែលទ្រង់ធ្វើ យើងខ្ញុំនឹងប្រុងប្រយ័ត្នថ្វាយការសរសើរ និងសិរីល្អទាំងអស់ដល់ទ្រង់តែមួយអង្គគត់។ យើងខ្ញុំ សូមអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន!

ការបង្រៀនតាមរយៈសំបុត្រ
ប្រតិចារិក: TL-L146-100-KHM
បច្ចុប្បន្នភាពចុងក្រោយ: 10 Nov 2026
គេហទំព័រ: Derekprince.com/km/resources

